# សេចក្តីថ្លែងការណ៍រួមរវាង LOLC និងដើមបណ្តឹង

នេះគឺជាសេចក្តីថ្លែងការណ៍រួម រវាងគ្រឹះស្ថាន អិលអូអិលស៊ី និង ដើមបណ្តឹង ពាក់ព័ន្ធនឹងការវិនិយោគដោយប្រយោលរបស់ IFC ជាមួយគ្រឹះស្ថាន អិលអូអិលស៊ី តាមរយៈទំនាក់ទំនងហិរញ្ញវត្ថុរបស់គ្រឹះស្ថានទាំងនេះជាមួយ MIFA (លេខគម្រោង IFC #31467)។ ពាក្យបណ្តឹងនេះត្រូវបានដាក់ឈ្មោះសម្គាល់ថា “Cambodia MIFA Debt Fund Amret MFI Equity 13”។

ជាលទ្ធផលនៃការចូលរួមដោះស្រាយវិវាទដោយស្ម័គ្រចិត្តដែលភាគីទាំងអស់បានចុះហត្ថលេខានៅក្នុងកិច្ចព្រមព្រៀងស្ថាពរ និងពេញលេញនៅថ្ងៃទី ១៦ ខែធ្នូឆ្នាំ ២០២៥ ហើយក្រុមសម្រុះសម្រួលរបស់ CAO បានចុះពិនិត្យតាមដានការអនុវត្តកិច្ចព្រមព្រៀងដោះស្រាយវិវាទរហូតដល់ចុងខែមិថុនាឆ្នាំ ២០២៦។

ភាគីទាំងពីរបានសំដែងនូវការពេញចិត្តចំពោះគ្នាទៅវិញទៅមកជាមួយលទ្ធផលនៃដំណើរការដោះស្រាយវិវាទ រួមទាំងវឌ្ឍនភាពនៃការអនុវត្តកិច្ចព្រមព្រៀងនេះផងដែរ។ ភាគីទាំងពីរបានយល់ស្របបញ្ចប់ការពិនិត្យតាមដានរបស់ CAO ផងដែរ។ ក្នុងអំឡុងពេលដែលការចូលរួមពិនិត្យតាមដានលើការអនុវត្តកិច្ចព្រមព្រៀងត្រូវបានបញ្ចប់ ភាគីទាំងពីរបានអះអាងបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការបន្តអនុវត្តចំណុចដែលនៅសេសសល់ទាំងអស់ឲ្យអស់នៅក្នុងកិច្ចព្រមព្រៀងនេះ។

កាលបរិច្ឆេទ៖ ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ២០២៦

ប្រើប្រាស់តែសម្រាប់គោលបំណងផ្លូវការប៉ុណ្ណោះ